# អរិយធម៌អូលមេក (Olmec civilization)

អូលមេកជាអរិយធម៌មួយដែលស្ថិតនៅក្នុងតំបន់ព្រៃត្រូពិក ក្បែរឈូងសមុទ្រម៉ិកស៊ិកូ ដែលបច្ចុប្បន្នជារដ្ឋ តាបាស្កូ( Tabasco) និង វេឡាគ្រូស (Veracruz) ស្ថិតនៅភាគខាងត្បូងនៃប្រទេសម៉ិកស៊ិកូ។[១] អរិយធម៌មួយនេះស្ថិតក្នុងចំណោមបណ្តាអរិយធម៌ចំណាស់ទាំង៣ នៅក្នុងតំបន់មេសូអាមេរិក(Mesoamerica) ឬតំបន់អាមេរិកកណ្តាល រួមមាន អរិយធម៌ អូលមេក(Olmec) ម៉ាយ៉ា (Maya) និង អតិច(Aztec)។[២]

អរិយធម៌អូលមេកត្រូវបានគេហៅជាភាសាអង់គ្លេសថា Pre-Colombian Culture ដែលមានន័យថា អរិយធម៌កើតឡើងមុនពេលដែល Christopher Columbus បានទៅដល់តំបន់អាមេរិកកណ្តាល។[៣] ចំពោះពាក្យ Olmec គឺមកពីពាក្យ Olmecatl នៃភាសា Nahuatl ដែលសំដៅលើប្រជាជនដែលដាំកៅស៊ូ (Rubber of country)។[៤]

នៅពាក់កណ្តាលស.វ.ទី១៩ អ្នកបុរាណវិទូបានរកឃើញវត្ថុសិល្បៈសំខាន់ៗដែលជាភស្តុតាងនៃការរកឃើញអរិយធម៌អូលមេក នៅតំបន់ខាងត្បូងប្រទេសម៉ិកស៊ិកូ។ តាមរយៈការសិក្សាបុរាណវិទ្យាបានបង្ហាញពីទីតាំងសំខាន់ៗចំនួន២ ដែលអ្នកស្រាវជ្រាវបានដឹងថាជាទីក្រុងបុរាណ និងជាតំបន់កណ្តាលនៃអរិយធម៌អូលមេក រួមមានតំបន់ San Lorenzo និង La Venta។[៥] តំបន់ San Lorenzo ដែលជាទីក្រុងដំបូងនៃអូលមេក (ស.វទី១៣មុនគ.ស ដល់១០មុនគ.ស)[៦] មានចម្ងាយប្រមាណជាង៥០គីឡូ ខាងត្បូងឈូងសមុទ្រម៉ិកស៊ិកូដែលបច្ចុប្បន្នជាទីក្រុង វេឡាគ្រូស (Veracruz) ហើយក៏ជាតំបន់នៃការរីកចម្រើននៃអរយិធម៌អូលមេកដំបូង និងបន្ទាប់មកទៀតនៅតំបន់ La Venta ដែលជាទីក្រុងបន្ទាប់ពី San Lorenzo ស្ថិតនៅ

---

[១] https://www.britannica.com/topic/Olmec

[២] *Ibid*

[៣] https://www.khanacademy.org/What do "Pre-Columbian" and "Mesoamerica" mean?

[៤] https://www.britannica.com/topic/Pre-columbian

[៥] https://www.nationalgeographic.org/olmec-civilization

[៦] Ann Cyphers , 1996

អត្ថបទដោយ៖ អេង តុលា

ក្បែរនឹងឈូងសមុទ្រម៉ិកស៊ិកូ ហើយបច្ចុប្បន្នជាទីក្រុង តាបាស្កូ (រូបលេខ១)។[៧] នៅតាមតំបន់ទាំងពីរ អ្នកស្រាវជ្រាវបានរកឃើញភស្តុតាងផ្សេងៗ រួមមានសំណង់ស្ថាបត្យកម្ម និងវត្ថុសិល្បៈផ្សេងៗដូចជា ត្បូង របាំងមុខ (រូបលេខ២)។ ជាពិសេសការរកឃើញរូបចម្លាក់ក្បាល ធ្វាក់ពីថ្ម ដែលមានទម្រង់មុខ មាត់ ច្រមុះ ភ្នែក ត្រចៀក ដូចនឹងទម្រង់មុខមនុស្សអញ្ចឹងដែរ ( Colossal stone heads) (រូបលេខ៣) និងសំណង់ពីរ៉ាមីតនៅ San Lorenzo ( Pyramid of San Larenzo) (រូបលេខ៤)។

អ្នកស្រាវជ្រាវបានរកឃើញរូបចម្លាក់ក្បាលប្រមាណ១៧រូប ដែលរូបចម្លាក់ទាំងនោះត្រូវបានរកឃើញដំបូងនៅទ.ស.ទី៤០នៅទីក្រុង San Lorenzo (Veracruz)។ ចំពោះប្រភពថ្មដែលយកមកធ្វាក់រូប អ្នកស្រាវជ្រាវបានដឹងថា យកពីភ្នំ Tuxtla ដោយទំហំនៃចម្លាក់ក្បាលទាំងនោះជា មធ្យមមានកម្ពស់ប្រមាណ៣ម៉ែត្រនិងមានទម្ងន់ប្រហែល៨តោន។[៨] រូបចម្លាក់ក្បាលទាំងនោះមានអាយុកាលប្រហែលចាស់ជាងស.វ.ទី១០មុនគ.ស. (រូបលេខ ៥-៦)។[៩]

យោងតាមទីតាំងភូមិសាស្ត្រ យើងអាចដឹងបានថា ប្រជាជនអូលមេករស់នៅក្នុងព្រៃទ្រពិកដែលពឹងលើការបរបាញ់សត្វព្រៃ និងនេសាទ។ អរិយធម៌អូលមេកត្រូវបានដួលរលំប្រហែលនៅស.វ.ទី៥មុនគ.ស ប៉ុន្តែពុំមានភស្តុតាងអ្វីមកបញ្ជាក់ពីកត្តានៃការដួលរលំនេះឱ្យច្បាស់លាស់បាននៅឡើយទេ ក្រៅពីការសន្និដ្ឋានដោយអ្នកស្រាវជ្រាវបុរាណវិទ្យាប្រហែលមកពីកត្តាធម្មជាតិ និងប្រហែលពីការឈ្លានពានពីអរិយធម៌ផ្សេងនៅតំបន់មេសូអាមេរិក។[១០]

តាមរយៈការសិក្សាលើភស្តុតាងដែលបានរកឃើញទាំងឡាយ អ្នកស្រាវជ្រាវបានបង្ហាញអរិយធម៌អូលមេកមានអាយុកាលជាង៨០០ឆ្នាំមុនគ.ស. ពោលចាប់ពី១២០០ឆ្នាំ

---

[៧] https://www.nationalgeographic.org/olmec-civilization

[៨] https://www.worldhistory.org: olmec-colossal-stone-heads

[៩] https://www.khanacademy.org: ancient-americas

[១០] *Ibid*

អត្ថបទដោយ៖ អេង តុលា

មុនគ.ស រហូតដល់៤០០មុនគ.ស.[១១] និងជាដើមកំណើត (Mother culture) នៃបណ្ដាអរិយធម៌ក្នុងតំបន់មេសូអាមេរិក (Mesoamerica)។[១២] យើងក៏ឃើញមានដាក់តាំងបង្ហាញរូបចម្លាក់នៃអរិយធម៌អូលមេកនៅក្នុងសារមន្ទីរ Quai Branly នៅប្រទេសបារាំង(រូបលេខ៧-៩)។




រូបលេខ១៖ ផែនទីបង្ហាញទីក្រុងសំខាន់ៗទាំងពីរនៃអរិយធម៌អូលមេក

ប្រភព៖ Wikimedia Commons

KHMER CIVILIZATION

[១១] https://www.science.org: roots-mesoamerican

[១២] Hector Neff , 2011, p.107-122

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៖ របាំងមុខ

ប្រភព៖ Wikimedia Commons



រូបលេខ៣៖ រូបចម្លាក់ក្បាលមនុស្ស ( Colossal stone heads )

ប្រភព៖ Wikimedia Commons

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៤៖ រូបចម្លាក់ក្បាលមនុស្ស
( Colossal stone heads )
ប្រភព៖ Wikimedia Commons



រូបលេខ២៥៖ រូបចម្លាក់ក្បាលមនុស្ស
( Colossal stone heads )
ប្រភព៖ Wikimedia Commons



រូបលេខ២៦៖ សំណង់ពីរ៉ាមីត ( Pyramid of San Lorenzo (Veracruz)

ប្រភព៖ https://www.khanacademy.org

ដោយ៖ អេង តុលា



រូបលេខ២៧៖ រូបចម្លាក់ដាក់តាំងបង្ហាញនៅក្នុងសារមន្ទីរ Quai branly ប្រទេសបារាំង

ប្រភព៖ https://www.quaibranly.fr



រូបលេខ២៨៖ រូបចម្លាក់ដាក់តាំងបង្ហាញនៅក្នុងសារមន្ទីរ Quai branly ប្រទេសបារាំង

ប្រភព៖ https://www.quaibranly.fr

អត្ថបទដោយ៖ អេង តុលា



រូបលេខ៩៖ រូបចម្លាក់ដាក់តាំងបង្ហាញនៅ
ក្នុងសារមន្ទីរ Quai branly ប្រទេសបារាំង
ប្រភព៖ https://www.quaibranly.fr

## ឯកសារយោង

Ann Cypher
1996. The Colossal Heads. In Olmecs (Areological Mexicana, Special Edition), pp. 48-55.
Clark J. &Pye. M
2000. Olmec art and archaeology in Mesoamerica.
Hector Neff
2011. The mother culture of Mesoamerica, p.107-122.

Website
https://www.britannica.com/topic/Olmec
https://www.khanacademy.org/What do “Pre-Columbian” and “Mesoamerica” mean?
https://www.britannica.com/topic/Pre-columbian
https://www.science.org: roots-mesoamerican
https://www.nationalgeographic.org/olmec-civilization

អត្ថបទដោយ៖ អេង តុលា